# Help Me Grow
Fresno County

**1-866-KIDS-HMG**
1-866-543-7464

សេវាកម្មយើងខ្ញុំនៅទីនេះដើម្បីឆ្លើយសំណួរទាំងអស់ របស់ លោក-អ្នក
អំពីកូនដែលកំពុងលូតលាស់ ។ យើងខ្ញុំក៏មានផ្តល់ជូន នូវការ
តាមដាន នៃលំដាប់ការលូតលាស់ នោះដោយឥតគិតថ្លៃ
សម្រាប់កុមារ អាយុក្រោម ៥ ឆ្នាំដើម្បីពិនិត្យមើលថា
តើពួកគេកំពុងលូតលាស់ យ៉ាងដូចម្តេច ។

**ឥតគិតកម្រៃនិងរក្សាភាពសម្ងាត់ជានិច្ច។**
**ចូលមើលគេហទំព័រ helpmegrow.fcoe.org**
**ផ្ញើសារ hmg@fcoe.org**





# ចាប់ផ្តើមពីចេះម្ហូរម៉ៅកិកក្អក រហូតដល់ដំណាក់ការចេះនិយាយ

**គ្មានសំណួរណាដែលតូចតាចឬធំឬមិនសំខាន់នោះទេ។**
**Help Me Grow អាចផ្តល់ចម្លើយដល់មាតាបិតានូវសំណួរទាំងឡាយ**
**ទាក់ទិននឹងការលូតលាស់របស់កុមារទាំងនោះ។**

# សេវាកម្មជំនួយផ្ដល់ដំណឹងនិងការបញ្ជូនទៅអ្នកឯកទេស ទាក់ទិននឹងការលូតលាស់នៃកុមារជាទីស្រឡាញ់របស់អ្នក ដោយមិនគិតកម្រៃ។

យើងខ្ញុំអាចជួយអ្នក ស្វែងរកក្រុមក្មេងលេងជាមួយគ្នា, ស្វែងយល់ថាតើពេលណាកូនរបស់អ្នកនឹងចាប់ផ្ដើមដើរ (ឬឈប់យំ!) ឬជួយត្រៀមកូនរបស់អ្នកឲ្យចូលសាលារៀន ។ យើងខ្ញុំអាចឆ្លើយសំនួររបស់អ្នក ឬបញ្ជូនទៅអ្នកឯកទេស ឲ្យឆ្លើយនឹងសំនួររបស់អ្នកក៏បាន ។

Help Me Grow អាចឆ្លើយនូវសំនួរដែលមានប្រចាំថ្ងៃ ទាក់ទិននឹងការលូតលាស់នៃកុមារជាទីស្រឡាញ់របស់អ្នក ។

**សូមទូរសព្ទទៅកាន់ 1-866 KIDS-HMG**

**1-866-543-7464**

**ចូលមើលគេហទំព័រ helpmegrow.fcoe.org**

**ឬ ផ្ញើសារ hmg@fcoe.org**



## គូសកំណត់សំគាល់នៃលំដាប់ការលូតលាស់ដែលកូនរបស់អ្នកបានឈានទៅដល់នោះ ហើយចែករំលែកនូវការលូតលាស់នេះ ជាមួយនឹងវេជ្ជបណ្ឌិត របស់អ្នករាល់ពេលទៅជួបពេទ្យនោះផងដែរ ។



**៦ ខែ**

- ☐ ត្រាប់តាមសូរសម្លេង
- ☐ ផ្ដើមអង្គុយដោយខ្លួនឯង
- ☐ ចូលចិត្តលេងជាមួយអ្នកដទៃ ជាពិសេសជាមួយនឹងឪពុកម្ដាយ
- ☐ តបនឹងឈ្មោះរបស់ខ្លួន
- ☐ ដាក់សម្លេងបញ្ចូលគ្នា ដូចជា ("អា," អេ,""អូ")



**១២ ខែ**

- ☐ ប្រើកាយវិការខ្លះដូចជាងក់ក្បាលសំរាប់បញ្ជាក់ថា "ទេ" ឬ លើកដៃបញ្ជាក់ថា "លាហើយ"
- ☐ ធ្វើត្រាប់តាមកាយវិការ
- ☐ តបទៅនឹងសំណើនិយាយសាមញ្ញ
- ☐ និយាយថា " ម៉ាក់" និង" ដាដា"
- ☐ ងើបឈរបាន



**១៨ ខែ**

- ☐ អាចនិយាយពាក្យបានខ្លះ
- ☐ ដើរដោយខ្លួនឯង
- ☐ ស្គាល់វត្ថុខ្លះដូចជាទូរសព្ទ ច្រាសស្លាបព្រា
- ☐ លេងប្រឌិតសាមញ្ញដូចជា បញ្ចុកចំណីឲ្យតុក្កតា
- ☐ ចង្អុលបង្ហាញអ្នកដទៃនូវអ្វីដែលខ្លួនចំណាប់អារម្មណ៍



**២ ឆ្នាំ**

- ☐ អាចនិយាយជាឃ្លាមានពី២ទៅ៤ពាក្យ
- ☐ រំភើបចិត្តពេលនៅជាមួយកុមារឯទៀតៗ
- ☐ អាចធ្វើតាមការបង្គាប់បន្ទាប់បន្សំ
- ☐ អាចទាត់បាល់
- ☐ ចង្អុលទៅវត្ថុឬរូបភាពតាមឮឈ្មោះគេប្រាប់



**៣ ឆ្នាំ**

- ☐ ត្រាប់តាមមនុស្សចាស់ឬមិត្តភក្តិ (ដូចជារត់ពេលឃើញក្មេងឯទៀតរត់)
- ☐ សន្ទនាគ្នាដោយប្រើ២ទៅ៣ឃ្លាបាន
- ☐ អាចឡើងបានដោយងាយ
- ☐ បង្កើតជារឿងប្រឌិត ដោយប្រើតុក្កតាសត្វឬមនុស្ស
- ☐ បង្ហាញសេចក្ដីស្រឡាញ់ចំពោះមិត្តភក្តិដោយមិនចាំបាច់ប្រាប់



**៤ ឆ្នាំ**

- ☐ លោតហើយឈរលើកជើងមួយរហូតដល់ ២ វិនាទី
- ☐ ចូលចិត្តលេងជាមួយក្មេងដទៃទៀតជាងនៅម្នាក់ឯង
- ☐ និទានរឿង
- ☐ គូររូបមនុស្សដែលមានបញ្ជាក់ផ្នែករាងកាយ ពី២ទៅ៤ផ្នែក
- ☐ លេងដោយសហការជាមួយអ្នកដទៃ

ខាងលើ នេះគឺគ្រាន់តែជាលំដាប់ការលូតលាស់សំខាន់ៗខ្លះ ដែលជាចំណុចកត់សំគាល់។

ដំណឹងបន្ថែមសូមទាក់ទងទូរសព្ទ**1-866-KIDS-HMG**

ចូលមើលគេហទំព័រ **helpmegrow.fcoe.org** ឬផ្ញើសារ **hmg@fcoe.org**